ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ .៦៣៩៩...សហវ .វស

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ២៧ ២២០ ៣៦២,៨២ ដុល្លារអាមេរិក សម្រាប់ធ្វើការជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកីចក ស្ថិតនៅក្នុងស្រុករមាសហែក ស្រុករំដួល ស្រុកស្វាយទាប ស្រុកកំពង់រោទិ៍ និងស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

**យោង:** លិខិតលេខ ០៥៦ ធទឧ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពជាគោលការណ៍ផ្តល់ថវិកាចំនួន ៥ ៩៥០ ០០០,០០ ដុល្លារអាមេរិក (ប្រាំលានប្រាំបួនរយហាសិបពាន់ ដុល្លារអាមេរិកគត់) ជូនក្រសួងធនធានទឹក និងឧតុនិយមសម្រាប់ធ្វើការជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកីចក សម្រាប់ការងារជំហានដំបូងក្នុងអនុគម្រោងទី១ និងទី២ (តាមគំនូសប្លង់នៃសំណើ) ដែលត្រូវផ្តោតលើការងារ ដូចខាងក្រោម:

-ស្តារប្រឡាយមេប្រវែង ៥ គីឡូម៉ែត្រ ចាប់ផ្តើមពីព្រែកកំពង់ស្ពាន

-សាងសង់សំណង់បង្ហៀរទឹក (spillway) ឆ្លងកាត់ព្រែកកំពង់ស្ពាន ចំនួន ០១ កន្លែង

-សាងសង់ស្ពានបេតុងឆ្លងកាត់ប្រឡាយមេ ចំនួន ០១ កន្លែង

-រៀបចំសហគមន៍អ្នកប្រើប្រាស់ទឹក

ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ ADB Loan No. 2480-CAM (SF) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន តាមការគួរ ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី
តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-សាលាខេត្តស្វាយរៀង

-មន្ទីរធនធានទឹក និងឧតុនិយមខេត្តស្វាយរៀង

-ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com